ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ

លេខ: ០៥០ ក.ជ.អ.ជ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភ ខេត្ត-ក្រុង

*****

## ប្រធានក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ /បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ០៧ / អនក្រ / បក ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ
- បានឃើញសារាចរ របស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០៥ សរ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅក្នុង ព្រះរាជាណាចក្រកម្ពុជា
- យោងតាមតំរូវការចាំបាច់

## សំរេច

**ប្រការ១:** បង្កើតគណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភ ខេត្ត-ក្រុង សំរាប់សំរបសំរួលការងារជាមួយបណ្តាមន្ទីរ អង្គភាពពាក់ពន្ធ័ក្នុងខេត្ត-ក្រុង ដើម្បីជំរុញការងារលើកកំពស់ស្ថានភាពអាហារូបត្ថម្ភ របស់ពលរដ្ឋខេត្ត-ក្រុង ឱ្យមានការរីកចំរើនរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកំពស់គុណភាពនៃជីវភាពរស់នៅរបស់

ប្រជាពលរដ្ឋ  អភិវឌ្ឍន៍ធនធានមនុស្ស  និង អភិវឌ្ឍន៍ខេត្ត-ក្រុង  ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

**ប្រការ២:** គណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត-ក្រុង មានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១- ឯកឧត្តមអភិបាលខេត្ត-ក្រុង | ប្រធាន |
| ២- ប្រធានមន្ទីរផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥- ប្រធានមន្ទីរអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- ប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ៧- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែនិងថាមពល | សមាជិក |
| ៨- ប្រធានមន្ទីរកិច្ចការនារី និងអតីតយុទ្ធជន | សមាជិក |
| ៩- ប្រធានមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | សមាជិក |
| ១០- ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ១១- ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២- ប្រធានមន្ទីរពត៌មាន | សមាជិក |

**ប្រការ៣:** គណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត-ក្រុង  មានភារកិច្ចដូចខាងក្រោម :

- ជំរុញការផ្សព្វផ្សាយអោយបានដល់ប្រជាពលរដ្ឋយល់ដឹងអំពីបញ្ហាអាហារូបត្ថម្ភ
- លើកផែនការសកម្មភាព និងកំណត់គោលដៅនៃការងារអាហារូបត្ថម្ភខេត្ត-ក្រុង
- សំរបសំរួលទាក់ទង និងរៀបចំបណ្តាញជាមួយមន្ទីរស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិក្នុងការអនុវត្តន៍ផែនការកម្មវិធីអាហារូបត្ថម្ភនានា
- តាមដាននិងវាយតំលៃការរីកចំរើននៃស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាពលរដ្ឋ ដោយយកចិត្តទុកដាក់ជាពិ-សេសទៅក្រុមជនងាយរងគ្រោះ
- បូកសរុបនិងធ្វើរបាយការណ៍អំពីលទ្ធផលការងារ ដែលបានសំរេចក្នុងការអនុវត្តន៍ផែនការសកម្មភាពអាហា-រូបត្ថម្ភ ជូនក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ ។

**ប្រការ៤:** គណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត-ក្រុង  មានលេខាធិការដ្ឋាន និងទីតាំងនៅមន្ទីរផែន-ការខេត្ត-ក្រុង ។

**ប្រការ៥:** សមាជិកគណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត-ក្រុង ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីប្រធានអវត្តមានអនុប្រធានអចិន្ត្រៃយ៍មានភារកិច្ចដឹកនាំ និងរៀបចំការប្រជុំជំនួស ។

**ប្រការ៦:** ប្រធានគណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត-ក្រុងមានសិទ្ធិអញ្ជើញមន្ត្រីជំនាញរបស់បណ្តាមន្ទីរពាក់ព័ន្ធ អង្គកាក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិផ្សេងៗទៀត ចូលរួមប្រជុំតាមករណីចាំបាច់ ។

**ប្រការ៧:** គណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត-ក្រុងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត-ក្រុង ។

**ប្រការ៨:** ឯកឧត្តម លោក លោកស្រី ដូចមានចែងក្នុងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាព ។

**ប្រការ៩:** សេចក្តីសំរេចនេះ មានប្រសិទ្ធិភាពចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី 22 ខែ 6 ឆ្នាំ២០០០*

**ប្រធានក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ**

៣២៥_៥៧

**ចំលងជូន**

- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- សមាជិកក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ
- សមាជិកគណៈកម្មការបច្ចេកទេសអន្តរក្រសួង
- គ្រប់សាលាខេត្ត-ក្រុង
- មន្ទីរផែនការគ្រប់ខេត្ត-ក្រុង
- អង្គការ UNICEF UNDP WHO FAO WFP HKI GTZ PFD Act Nord Sud

"ដើម្បីជ្រាបជាពត៌មាន"

- ដូចប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ